អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ២០២១*

# សេចក្តីជូនដំណឹង
# ព័ត៌មានស្តីពីការចូលរួមរបស់សាធារណជន និងអ្នកសារព័ត៌មាន
# នៅក្នុងសវនាការលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០២ ប្រឆាំងនឹង ខៀវ សំផន

អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានកំណត់កាលវិភាគសម្រាប់សវនាការលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០២ប្រឆាំងនឹងខៀវ សំផនដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃច័ន្ទ ទី១៦ ដល់ថ្ងៃព្រហស្បតិ៍ ទី១៩ ខែ សីហា ឆ្នាំ២០២១ នៅវេលាម៉ោង៩ព្រឹក។ អង្គជំនុំជម្រះបានត្រៀមថ្ងៃបម្រុងសម្រាប់សវនាការ ក្នុងករណីចាំបាច់ ពីថ្ងៃសុក្រ ទី២០ ដល់ថ្ងៃទីសុក្រ ទី២៧ ខែសីហា ឆ្នាំ២០២១(រយៈពេល៦ថ្ងៃ)។

## ព័ត៌មានសម្រាប់អ្នកចូលរួម និងអ្នកសារព័ត៌មាន

ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃកូវីឌ-១៩ ក្នុងសាលសវនាការនឹងត្រូវផ្តល់ជូនកន្លែងអង្គុយចំនួន ៥០កន្លែងប៉ុណ្ណោះដែលនឹងបែងចែកដូចខាងក្រោម៖

### ១. ដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង០០២ និងតំណាងផ្លូវច្បាប់

កន្លែងអង្គុយចំនួន១០ ត្រូវបានត្រៀមទុកសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានសម្របសម្រួលដោយអង្គភាពគាំពារជនរងគ្រោះ អង្គការអន្តរការី និងតំណាងផ្លូវច្បាប់របស់គាត់។

### ២. ភ្ញៀវអង្គទូត និងតំណាងរដ្ឋាភិបាល

កន្លែងអង្គុយចំនួន១៥ ត្រូវបានត្រៀមទុកសម្រាប់ភ្ញៀវអង្គទូត និងតំណាងរដ្ឋាភិបាល។ សូមចុះឈ្មោះកក់កន្លែងជាមុនតាមរយៈសារអេឡិចត្រូនិក pas@eccc.gov.kh។ ការចុះឈ្មោះកក់កន្លែងទុកជាមុននឹងផុតកំណត់នៅថ្ងៃអង្គារ ទី១០ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង៤ រសៀល។

### ៣. តំណាងសារព័ត៌មាន

កន្លែងអង្គុយចំនួន១៥ នៅក្នុងសាលសវនាការ ត្រូវបានត្រៀមទុកសម្រាប់តំណាងសារព័ត៌មាន ហើយសមាជិកសារព័ត៌មានដែលនៅសេសសល់ នឹងត្រូវផ្តល់កន្លែងអង្គុយនៅក្នុងបន្ទប់សារព័ត៌មាន C108 នៅជាន់ផ្ទាល់ដីនៃអគារតុលាការ។

ការចុះឈ្មោះកក់ទុកកន្លែងអង្គុយជាមុនក្នុងសាលសវនាការសម្រាប់អ្នកសារព័ត៌មាន ត្រូវធ្វើឡើងតាមរយៈសារអេឡិចត្រូនិក pas@eccc.gov.kh មិនឲ្យហួសពីថ្ងៃអង្គារ៍ ទី១០ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង៤ រសៀល។

**៤. តំណាងអង្គការសង្គមស៊ីវិល និងសាធារណជនទូទៅ**

កន្លែងអង្គុយចំនួន១០ នឹងត្រូវត្រៀមសម្រាប់តំណាងសង្គមស៊ីវិលនិងសាធារណជនទូទៅហើយត្រូវផ្ដល់ជូនដល់អ្នកដែលបានចុះឈ្មោះជាមុន។ ទ្វារចូលសម្រាប់ភ្ញៀវនឹងបើកនៅម៉ោង៧ព្រឹក។ អ.វ.ត.កណែនាំឱ្យអ្នកចូលរួមគួរតែមកដល់ អ.វ.ត.ក ឱ្យបានមុន ដើម្បីទុកពេលវេលាគ្រប់គ្រាន់សម្រាប់ការត្រួតពិនិត្យសន្តិសុខ និងការចែកសំបុត្រចូល។ អ.វ.ត.ក នឹងបិទច្រកចូលទៅកាន់សាលសវនាការនៅម៉ោង៨.៤៥នាទីព្រឹក ឬនៅពេលដែលសាលសវនាការមានអ្នកចូលរួមអង្គុយគ្រប់ចំនួនកំណត់។

សូមរំឭកថា ដើម្បីចូលក្នុងសាលសវនាការ អ្នកចូលរួមទាំងអស់ត្រូវបង្ហាញប័ណ្ណសម្គាល់ខ្លួនដល់សន្តិសុខនៅច្រកមាត់ទ្វារខាងក្រៅ។ អ្នកចូលរួម តម្រូវឱ្យអនុវត្តតាមនីតិវិធីកាត់បន្ថយហានិភ័យនៃការឆ្លងកូវីដ-១៩ តាមការណែនាំរបស់មន្ត្រីសន្តិសុខ អ.វ.ត.ក មានដូចជា អនាម័យដៃ ការពាក់ម៉ាស និងគំលាតសុវត្ថិភាពសមស្រប នៅពេលអង្គុយក្នុងសាលសវនាការ និងនៅពេលដើរជុំវិញបរិវេណ អ.វ.ត.ក។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖
ឯកឧត្តម **នេត្រ ភក្ត្រា**
ប្រធានផ្នែកកិច្ចការសាធារណៈ និងជាមន្ត្រីនាំពាក្យ
ទូរស័ព្ទលេខ៖ +៨៥៥ (0) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh